ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៦៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

**លោក ហ៊ុន តូ**

ជា

**អ្នកឧកញ៉ា**

ព្រះហស្តលេខា

ទាំង

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ

ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០០

★★★

# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៥ អនក្រ.បក

### ស្តីពីការលុបចោលដីកាលេខ ១៦៧ សសរ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ១៩៩៩ និងដីកាលេខ ០៩២ សសរ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ របស់សាលាខេត្តសៀមរាប

រាជរដ្ឋាភិបាល

- បានពិនិត្យរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានពិនិត្យព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣០/សហ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរលេខ ០៦/សរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីវិធានការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និង ការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- យោងតាមការពិនិត្យភាពមិនប្រក្រតី នៃលិខិតលេខ ១៦៧ សសរ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ និង លិខិតលេខ ០៩២ សសរ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ របស់សាលាខេត្តសៀមរាប

## សំរេច

**មាត្រា ១.-** លុបចោលលិខិតលេខ ១៦៧ សសរ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់សាលាខេត្តសៀមរាប ស្តីពីការដូរ-ប្រគល់ទីតាំងស្ថិតនៅភូមិខ្នារ ឃុំជ្រាវ ស្រុកសៀមរាប សំរាប់ធ្វើជាចំណតរថយន្តតាក់ស៊ី រថយន្តដឹកអ្នកដំណើរ និងទំនិញគ្រប់ប្រភេទ ដែលមានផ្ទៃដីទំហំ ១២.៧២៥ ម² ដែលចុះហត្ថលេខាដោយអភិបាលរងទី១ ខេត្តសៀមរាប ដោយមូលហេតុការដូរ-ប្រគល់ នេះមានភាពមិនប្រក្រតី ។

និងលុបចោលលិខិតលេខ ០៩២ សសរ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការប្រគល់ទីតាំងដីអូរបាក់ឆ្អឹងស្ថិតក្នុងភូមិខ្នារ ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ជូនទៅលោក មួក សៀ ដែលមានទំហំ ២១.៩០០ម² ដែលចុះហត្ថលេខាដោយឯកឧត្តមអភិបាលខេត្តសៀមរាប ដោយមូលហេតុការប្រគល់នេះ មានភាពមិនប្រក្រតី ។

**មាត្រា ២.-** ការគ្រប់គ្រង និងការប្រើប្រាស់ដីដែលចែងក្នុងមាត្រា ១ ខាងលើនេះ នឹងត្រូវកំណត់ដោយអនុក្រឹត្យមួយផ្សេងទៀត ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរអប្សរា អភិបាលខេត្ត សៀមរាប

www.pheakdeylaw.com

ក្រុមហ៊ុនអ៊ិចស៊ីលេរ៉ាត និងតំណាងរបស់ក្រុមហ៊ុន លោក ឡុក គៀរ៉ា និងគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ២៦ អនក្រ .បក**

**ស្តីពីការកែសំរួលមុខងារនិងភារកិច្ច**

**និងការបង្កើតគ្រួមមួលគល្បាប់ និង នាយកដ្ឋាន**

**សហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន នៃ ក្រសួងទេសចរណ៍**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៥ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

www.pheakdeylaw.com